ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

លេខ: ៥៣ "ឆ"

ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២

សំណុំរឿងរដ្ឋប្បវេណី

លេខ ៥៧៥

ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង បី រសៀល ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ [redacted] សុវណ្ណភួងសម្ផស្ស ភេទស្រី អាយុ២៤ឆ្នាំ ទីលំនៅសព្វថ្ងៃ [redacted]។

-អ្នកតំណាងដោយអាណត្តិលោកស្រីមេធាវី [redacted] និងលោកស្រី [redacted] មានអាសយដ្ឋាន [redacted]

-ចុងចម្លើយឈ្មោះ [redacted] ហ៊ុកវណ្ណ ភេទប្រុស ទីលំនៅ [redacted]។

### I <u>អង្គហេតុ និងបំណុចវិវាទ</u>

**ក) <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖</u>**

១-ប្តឹងសុំអោយតុលាការចេញសាលក្រមលែងលះពីប្តីឈ្មោះ [redacted] ហ៊ុកវណ្ណ។

២-ប្តឹងសុំអោយតុលាការចេញសាលក្រមជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ។

**ខ) <u>ការពន្យល់ត្រួសៗអំពីរឿងក្តី៖</u>**

តាមពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] សុវណ្ណភួងសម្ផស្ស បានបញ្ជាក់ ថា៖ ខ្លួនសុំលែងលះពីប្តីដោយហេតុថា ការរស់នៅជាមួយគ្នាមិនចុះសម្រុងនិងគ្នា ចេះតែមានបញ្ហារកាំរកូសជាមួយគ្នាជាញឹកញ៉ាប់ ទើបធ្វើអោយខ្លួន និងប្តីអស់មនោសញ្ចេតនាជាមួយគ្នា ទើបសម្រេចចិត្តលែងលះគ្នា។ ហើយខ្លួននិងប្តី មានកូនមួយនាក់ឈ្មោះ [redacted] វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ ៨ខែ ខ្លួនសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូនដោយ ទាមទារអាហារកាតព្វកិច្ចតាមលទ្ធភាពរបស់ប្តី។

**គ) <u>ការអះអាងរបស់ភាគីដើមចោទ</u>**

-ដើមចោទឈ្មោះ [redacted] សុវណ្ណភួងសម្ផស្ស បានថ្លែងការណ៍ថា: ខ្លួនសុំលែងលះពីប្តីដោយហេតុថា ការរស់នៅជាមួយគ្នាមិនចុះសម្រុងនិងគ្នា ចេះតែមានបញ្ហារកាំរកូសជាមួយគ្នាជាញឹកញ៉ាប់ ទើបធ្វើអោយខ្លួន និងប្តីអស់



Scanned with CamScanner

មនោសញ្ចេតនាជាមួយគ្នា ទើបសម្រេចចិត្តលែងលះគ្នា។ ហើយខ្លួន និងប្តី មានកូនមួយនាក់ឈ្មោះ [redacted] វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ ៨ខែ ខ្លួនសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូន ដោយ ទាមទារអាហារកាតព្វកិច្ចតាមលទ្ធភាពរបស់ប្តី។ ក្រៅពីនេះខ្លួន និងប្តីមិនមានទ្រព្យរួម និងបំណុលរួមទេ។

ឃ) <u>ការអះអាងតបរបស់ភាគីចុងចម្លើយ</u>

-ចុងចម្លើយឈ្មោះ [redacted] ហ៊ុកវណ្ណ បានថ្លែងការណ៍ថា: ខ្លួនឯកភាពលើគ្រប់ចំនុចនៃការទាមទាររបស់ដើមចោទ ដោយស្ម័គ្រចិត្តលែងលះគ្នា ព្រោះតែការរស់នៅជាមួយគ្នាមិនចុះសម្រុងពិតមែន ហើយតែងតែមានបញ្ហារកាំរកូសជាមួយគ្នាមែន។ ចំពោះកូន ខ្លួនសុខចិត្តប្រគល់ឲ្យប្រពន្ធជាអ្នកមានអំណាចមេបា ដោយព្រមផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។ ក្រៅពីនេះខ្លួន និងប្រពន្ធមិនមានទ្រព្យរួម និងបំណុលរួមទេ។ ហើយកិច្ចព្រមព្រៀង លែងលះ ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០២១ ខ្លួននិងប្រពន្ធ ពិតជាធ្វើឡើងដោយស្ម័គ្រចិត្ត។

ង-<u>ចំណុចវិវាទ:</u> គ្មាន។

<u>ច-ចំណុចគ្មានវិវាទ:</u>

-ដើមចោទ និងចុងចម្លើយ ឯកភាពលែងលះគ្នា។

-ដើមចោទ និងចុងចម្លើយ ឯកភាពប្រគល់សិទ្ធិជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ៨ខែ ឲ្យទៅឈ្មោះ [redacted] សុវណ្ណភួងសម្ផស្ស។

-ដើមចោទ និងចុងចម្លើយ ឯកភាពគ្មានទទួលការផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនពីឈ្មោះ [redacted] ហ៊ុកវណ្ណ តាមលទ្ធភាព។

## II.**ការពិនិត្យភស្តុតាង**

**១ ភស្តុតាងជាឯកសាររបស់ដើមចោទ:**

**១.១**-សំបុត្រអាពាហ៍ពិពាហ៍លេខ ៧៧ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចេញដោយសង្កាត់ភ្នំពេញថ្មី ។

**១.២**-សំបុត្របញ្ជាក់កំណើតលេខ ១៤០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចេញដោយសង្កាត់ភ្នំពេញថ្មី ។

**១.៣**-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុវណ្ណភួងសម្ផស្ស និងឈ្មោះ [redacted] ហ៊ុកវណ្ណ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផល នៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាងនានាក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា៖

១-ដើមចោទ និងចុងចម្លើយ ឯកភាពគ្នាលែងលះពីគ្នា ដោយសារតែការរស់នៅជាមួយគ្នាមិនចុះសម្រុង និងគ្នា ចេះតែមានបញ្ហារកាំរកូសជាមួយគ្នាជាញឹកញ៉ាប់ ទើបធ្វើអោយពួកខ្លួនអស់មនោសញ្ចេតនាជាមួយគ្នាទៀត។ តុលាការ យល់ឃើញថា ភាគីព្រមព្រៀងគ្នាលែងលះដោយស្ម័គ្រចិត្ត ពិតមែន ដូចនេះ គប្បីតុលាការពិចារណាតាមការសម្រេចចិត្តរបស់ភាគី។

២-ដើមចោទប្តឹងទាមទារសិទ្ធិជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ ៨ខែ ដោយសុខចិត្តទទួលអាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាពពីចុងចម្លើយ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

៣-តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៧៧ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចេញដោយ សង្កាត់ភ្នំពេញថ្មី

បានបញ្ជាក់ថាគូភាគីពិតជាប្តី-ប្រពន្ធ ភ្ជាពិតមែន។

៤-តាមសំបុត្របញ្ជាក់កំណើតលេខ ១៤០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ចេញដោយ សង្កាត់ភ្នំពេញថ្មី បានបញ្ជាកថាគូភាគីពិតជាមានកូនចំនួនមួយនាក់ឈ្មោះ [redacted]វណ្ណៈរាជ្យ ភេទប្រុស អាយុ៣ឆ្នាំ ៨ខែ។

៥-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

<u>**សេចក្តីសម្រេចបញ្ចប់**</u>

១) ឲ្យឈ្មោះ [redacted] **សុវណ្ណត្នូខសម្ផស្ស** ភេទស្រី អាយុ២៤ឆ្នាំ និងឈ្មោះ [redacted] **ហ៊ុកវណ្ណា** ភេទប្រុស អាយុ២៤ឆ្នាំ លែងលះតាមការព្រមព្រៀង ។

២) ឲ្យឈ្មោះ [redacted] **សុវណ្ណត្នូខសម្ផស្ស** ភេទស្រី អាយុ២៤ឆ្នាំ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] **វណ្ណៈរាជ្យ** ភេទប្រុស។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិសួរសុខទុក្ខ ជួបប្រាស្រ័យទាក់ទងកូន បានគ្រប់ពេលវេលា នៅពេលថ្ងៃ ហើយភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ផ្អែកតាមមាត្រា **១០៣៤, ១០៣៧** នៃក្រមរដ្ឋប្បវេណី។

៣) ឲ្យឈ្មោះ [redacted] **ហ៊ុកវណ្ណា** ផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ឲ្យទៅឈ្មោះ [redacted] **សុវណ្ណត្នូខសម្ផស្ស** តាមមាត្រា **១០៤០** នៃ ក្រមរដ្ឋប្បវេណី។

៤) ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រមជាសាធារណៈ នាថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រម:**

**ហត្ថលេខា និងត្រា:**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធស័ករាជ ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]